| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | ចិត្តចលភាព/បុរេគណិត |
| **ប្រធានបទ** | ចិតចលភាព៖<br>-ការរីកចម្រើនរាងកាយ និងចលនា<br>បុរេគណិត៖<br>-ស្គាល់ពីពណ៌ និងចំនួនពណ៌ |
| **ចំណងជើងមេរៀន** | ល្បែងដណ្តើមពណ៌<br>(ដកស្រង់ពីសៀវភៅរឿងតើនរណាជាអ្នកលាបពណ៌មេឃ) |
| **កម្រិត** | ទាប |
| **គោលបំណង** | ការបង្កើនកម្លាំង និងការប្រឈមទប់ទល់នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព(រត់ ដើរ លោត។ ដើម្បីឱ្យកុមារស្គាល់ពណ៌។ |
| **បំណិនសម្បទា** | ធ្វើចលនាដើរ និងរត់ទៅតាមសកម្មភាពផ្សេងៗ។ |
| **ចរិយាសម្បទា** | ព្យាយាម អំណត់ ស្វាហាប់ រហ័សរហួន ទន់ភ្លន់ ប្រុងប្រយ័ត្ន និងសប្បាយរីករាយ។ |
| **គ្រូបង្រៀន(សម្ភារឧបទេស)** | - អ៊ុតក្រដាសពណ៌ និងកាត់វាជា៨ចំណែក ដើម្បីធ្វើជាកាត។<br>-ត្រូវមានកាតគ្រប់គ្រាន់សម្រាប់ក្មេងម្នាក់ៗ(ឬប្រើគម្របដបពណ៌ជំនួសក៏បាន)។ |
| **កុមារ** | ឈរជុំវិញកៅអី |

| រៀបចំ | កន្លែងលេង(ក្នុងថ្នាក់ឬក្រៅថ្នាក់ទៅតាមចំនួនកុមារ)។ |
|---|---|

| សកម្មភាពគ្រូបង្រៀន | សកម្មភាពសិស្ស |
|---|---|
| 1. ច្រៀងB3-MP3-1_បទឥន្ទធនូ<br>2. ចែកកាតពណ៌ឱ្យទៅក្មេងៗម្នាក់មួយសន្លឹកៗ។<br>3. ពួកគេត្រូវឈរនៅចំកន្លែងកៅអីរបស់ខ្លួន និងដើរនៅមួយកន្លែង ឬទៅមុខជុំវិញកៅអីក៏បាន។<br>4. លោកគ្រូ អ្នកគ្រូស្រែកហៅពណ៌មួយ និងបន្តស្រែកហៅពណ៌ទៀត (ឧ. "ក្រហម ៗ" )<br>5. ក្មេងៗដែលមានពណ៌ដូចដែលអ្នកស្រែកបានស្រែកនោះត្រូវអង្គុយចុះទាំងអស់។ ចំពោះក្មេងៗណាដែលអង្គុយទាំងដែលខ្លួនមិនមានពណ៌ដូចដែលអ្នកស្រែកបានស្រែកនោះពួកគេនឹងត្រូវចាញ់ ហើយត្រូវទៅឈរនៅកន្លែងខាងមុខ។<br>6. នៅពេលដែលក្មេងទាំងអស់អង្គុយចុះ ពួកគេត្រូវលើកកាតពណ៌ដែលខ្លួនកាន់បង្ហាញទៅគ្រូ(ប្រាកដមានកាតទាំងប្រាំពីរកាន់)<br>7. ប្រសិនបើអ្នកស្រែកពាក្យថា «ឥន្ទធនូ» ក្មេងៗទាំងអស់ត្រូវអង្គុយចុះ ។<br>8. បន្ទាប់ពីនិយាយពណ៌នីមួយៗរួច ឱ្យក្មេងៗទាំងអស់ក្រោកឈរម្តងទៀត បន្ទាប់មក និយាយពណ៌ផ្សេងទៀត | 1. ច្រៀងB3-MP3-1_បទឥន្ទធនូ និងធ្វើកាយវិការដែរ<br>2. ត្រូវចាំថាអ្នកទទួលបានពណ៌អ្វី<br>3. ដើរជុំវិញនៅកន្លែងកៅអីរបស់អ្នក។<br>4. ប្រសិនបើគ្រូហៅពណ៌របស់អ្នក ឬហៅឥន្ទធនូ សូមអង្គុយចុះ។<br>5. ប្រសិនបើគ្រូហៅពណ៌ផ្សេងដែលមិនមែនជាពណ៌របស់អ្នក អ្នកមិនត្រូវអង្គុយទេ ត្រូវនៅឈរដដែល ។<br>6. ប្រសិនបើអ្នកជាមនុស្សចុងក្រោយ ឬតែម្នាក់ដែលនៅឈរ អ្នកនឹងក្លាយជាអ្នកហៅពណ៌វិញម្តង។ ប៉ុន្តែត្រូវហៅពណ៌ទាំង៧ឱ្យបានត្រឹមត្រូវ ដើម្បីឱ្យក្មេងទាំងអស់ចេះ និងស្គាល់ពណ៌ទាំងនោះ។<br>7. បន្ទាប់ពីហៅពណ៌គ្រប់គ្នាហើយ ឱ្យក្មេងៗទាំងអស់ក្រោកឈរម្តងទៀត<br>8. ច្រៀងB3-MP3-1_បទឥន្ទធនូម្តងទៀត និងធ្វើកាយវិការផង |

| | |
|---|---|
| 9. ក្មេងៗចុងក្រោយដែលនៅសល់អាចក្លាយជាអ្នកស្រែក ហៅពណ៌វិញម្តង។<br>10. ច្រៀងB3-MP3-1_បទឥន្ទធនូទាំងអស់គ្នាម្តងទៀត | |